# សិទ្ធិរបស់ ស្ត្រី ជនជាតិ ដើម ភាគតិច




# នៅក្នុងកិច្ចអភិវឌ្ឍន៍

# អារម្ភកថា

"សិទ្ធិរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងកិច្ចអភិវឌ្ឍន៍" គឺជាចំណងជើងរបស់សៀវភៅរូបភាព ដែលបង្ហាញអំពីសិទ្ធិទាំងឡាយដែលស្ត្រីជនជាតិដើមភាគតិចទទួលបានដូចស្ត្រីទូទៅផងដែរ។

សៀវភៅនេះ បានចងក្រងឡើងសម្រាប់លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ ជាពិសេស សហគមន៍ជនជាតិដើមភាគតិច ដែលផ្តោតសំខាន់ទៅលើសិទ្ធិរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងការចូលរួម ការងារអភិវឌ្ឍន៍ និងការសម្រេចចិត្តនៅក្នុងសង្គម។ ទន្ទឹមនឹងនេះ គោលបំណងសំខាន់ គឺកុំអោយមានការរើស អើងពួកគាត់ទាំងនៅក្នុងក្រុមគ្រួសារ និងសង្គម តាមរយៈការចែករំលែកនូវការងាររបស់ស្ត្រី ដើម្បីអោយ ពួកគាត់មានឱកាសចូលរួមក្នុងកិច្ចការងារអភិវឌ្ឍន៍បាន (ទំនួលការងារយេនឌ័រ)។

បោះពុម្ពខែ ធ្នូ ឆ្នាំ២០១២
ការិយាល័យឌីភីអេ កម្ពុជា
ផ្ទះលេខ៦៩ហ្សិត , ផ្លូវលេខ៤៥០, ទួលទំពូងII , ភ្នំពេញ កម្ពុជា
ប្រអប់សំបុត្រលេខ ៥ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២១៦ ៣៦៩/២១៦ ៤៩៥
អ៊ីម៉េល ៖ dpa.reception@dpacam.org
គេហទំព័រ ៖ www.dpacam.org

# ហេតុអ្វីបានជាការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងកិច្ច
# អភិវឌ្ឍន៍នៅមានចំនួនតិចតួច ?



ព្រោះពួកគាត់មានការមមាញឹកនឹង
ការងារផ្ទះ និងរបរចិញ្ចឹមជីវិត

# ហេតុអ្វីបានជាការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងកិច្ចអភិវឌ្ឍន៍នៅមានចំនួនតិចតួច ?




*ភាពមិនចេះអក្សរ ជាកត្តាចម្បងមួយដែលជម្រុញអោយស្ត្រីជនជាតិដើមភាគតិចភាគច្រើនគិតថាខ្លួនឯង គ្មានសមត្ថភាព និងគ្មានទំនុកចិត្តលើខ្លួនឯង*

# ហេតុអ្វីបានជាការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងកិច្ចអភិវឌ្ឍន៍នៅមានចំនួនតិចតួច ?



ខ្វះការគាំទ្រ និងលើកទឹកចិត្តពីសំណាក់ក្រុមគ្រួសារ និងសហគមន៍របស់ខ្លួន រឺ ពីសង្គម

# ហេតុអ្វីបានជាការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងកិច្ចអភិវឌ្ឍន៍នៅមានចំនួនតិចតួច ?



ភាពក្រីក្រក៏ជាកត្តាសំខាន់មួយដែលកម្រិតការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិច

# ហេតុអ្វីបានជាការចូលរួមរបស់ស្ត្រីជនជាតិដើមភាគតិចនៅក្នុងកិច្ចអភិវឌ្ឍន៍នៅមានចំនួនតិចតួច ?




ស្ត្រីជនជាតិដើមភាគតិចភាគច្រើន នៅមិនទាន់យល់ច្បាស់ទៅលើសិទ្ធិផ្សេងៗ ដែលពួកគេមាន

# ហេតុអ្វីបានជាត្រូវការស្ត្រីជនជាតិដើមភាគតិចចូលរួមក្នុងកិច្ចអភិវឌ្ឍន៍និងការសម្រេចចិត្តនៅក្នុងសង្គម?



ស្ត្រីជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការដឹកនាំ និងអភិវឌ្ឍន៍សហគមន៍របស់ពួកគាត់ (ពួកគាត់អាចជាអាជ្ញាធរ ជាចាស់ព្រឹទ្ធាចារ្យ អ្នកមើលថែទាំគ្រួសារ រឺ ជាឆ្មបម្នាក់នៅក្នុងភូមិ)

# ហេតុអ្វីបានជាត្រូវការស្ត្រីជនជាតិដើមភាគតិចចូលរួមក្នុងកិច្ចអភិវឌ្ឍន៍និងការសម្រេចចិត្តនៅក្នុងសង្គម ?



ស្ត្រីជនជាតិដើមភាគតិចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមធ្វើសេចក្តីសម្រេចចិត្តលើការងារសំខាន់ៗ ដែលពាក់ព័ន្ធនឹងអនាគតសហគមន៍របស់ពួកគេ (ការបង្កើននូវសុខុមាលភាព និងការអភិវឌ្ឍសហគមន៍ ដែលឆ្លើយតបទៅនឹងតំរូវការ)

# ហេតុអ្វីបានជាត្រូវការស្ត្រីជនជាតិដើមភាគតិចចូលរួមក្នុងកិច្ចអភិវឌ្ឍន៍និងការសម្រេចចិត្តនៅក្នុងសង្គម?



បញ្ហាអ្វីៗត្រូវបានដោះស្រាយ (ឧទាហរណ៍៖ អំពើហិង្សាលើស្ត្រី និងកុមារ , ការជួញដូរផ្លូវភេទស្ត្រី និងកុមារ , ការអប់រំសុខភាព , ការគ្រប់គ្រងធនធានធម្មជាតិ រឺ ទំនាស់ដីធ្លីជាដើម)

# ហេតុអ្វីបានជាត្រូវការស្ត្រីជនជាតិដើមភាគតិចចូលរួមក្នុងកិច្ចអភិវឌ្ឍន៍និងការសម្រេចចិត្តនៅក្នុងសង្គម?



ការចូលរួមរបស់ស្ត្រីជាមួយនឹងបុរស អាចកាត់បន្ថយភាពក្រីក្រក្នុងគ្រួសារ និងសង្គមជាតិ

# តើសិទ្ធិអ្វីខ្លះដែលស្ត្រីជនជាតិដើមភាគតិចអាចទទួលបាន?

មាត្រា២នៃសេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពី សិទ្ធិជនជាតិដើមភាគតិច បានចែងថា "ជនជាតិដើមភាគតិច និងបុគ្គលជនជាតិជនជាតិដើមភាគតិចមានសេរីភាព និងសមភាពដូចប្រជាពលរដ្ឋ និងបុគ្គលដទៃទៀត ព្រមទាំងសិទ្ធិរួចចាកផុតពីការរើសអើងគ្រប់រូបភាពក្នុងការអនុវត្តសិទ្ធិ ជាពិសេសដោយផ្អែកលើមូលហេតុ នៃដើមកំណើត ឬ អត្តសញ្ញាណរបស់ខ្លួនជាជនជាតិដើមភាគតិច។" ទន្ទឹមនឹងនេះរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣៤ និង៣៥ បានចែងថា ៖ បុរស និងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងការទទួលយកឱកាស និងផលប្រយោជន៍ពីសង្គម។

ដោយឡែកនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលហៅកាត់ថា ស៊ី-ដ ដែលជាសន្ធិសញ្ញាអន្តរជាតិដំបូងគេ ដែលបានបញ្ជាក់យ៉ាងទូលំទូលាយអំពីសិទ្ធិរបស់នារី ដែលត្រូវតែមានក្នុងបរិបទស៊ីវិល នយោបាយ ជីវិតសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងជីវិតគ្រួសារ។



# តើសិទ្ធិអ្វីខ្លះដែលស្ត្រីជនជាតិដើមភាគតិចអាចទទួលបាន ?




សិទ្ធិទទួលបានការអប់រំ

# តើសិទ្ធិអ្វីខ្លះដែលស្ត្រីជនជាតិដើមភាគតិចអាចទទួលបាន?




សិទ្ធិទទួលបានសេវាសុខភាព

# តើសិទ្ធិអ្វីខ្លះដែលស្ត្រីជនជាតិដើមភាគតិចអាចទទួលបាន?



សិទ្ធិទទួលបានការងារ ផលប្រយោជន៍ និងសន្តិសុខសង្គម

# តើសិទ្ធិអ្វីខ្លះដែលស្ត្រីជនជាតិដើមភាគតិចអាចទទួលបាន ?



សិទ្ធិទទួលបានសេរីភាព ដោយចាកផុតពីរាល់ទម្រង់នៃអំពើហិង្សាលើរាងកាយ ភេទ ចិត្ត អារម្មណ៍ សេដ្ឋកិច្ច ទាសភាព និងពេស្យាចារ

# តើសិទ្ធិអ្វីខ្លះដែលស្ត្រីជនជាតិដើមភាគតិចអាចទទួលបាន?



សិទ្ធិទទួលបានការបោះឆ្នោត ឈរឈ្មោះអោយគេបោះឆ្នោត រៀបចំការបោះឆ្នោត
និងកាន់តំណែងក្នុងការិយាល័យសាធារណៈ

លើកកម្ពស់ និងគាំទ្រចំពោះស្ត្រី ជាពិសេសស្ត្រីជនជាតិដើមភាគតិចដើម្បីបង្កើនការចូលរួមរបស់ពួកគេក្នុងកិច្ចអភិវឌ្ឍន៍ និងការសម្រេចចិត្តនៅក្នុងសង្គម តាមរយៈ៖

- ផ្តល់ឱកាស និងលើកទឹកចិត្តដល់ស្ត្រី
- ពង្រឹងសមត្ថភាពស្ត្រី
- សហការជាមួយស្ត្រីអោយបានល្អ
- ជម្រុញស្ត្រីអោយមានភាពក្លាហានក្នុងការសម្រេចចិត្ត
- ចែករំលែកការងារផ្ទះជាមួយស្ត្រី
- លើកកម្ពស់ការយល់ដឹងរបស់ស្ត្រីជនជាតិដើមភាគតិចអំពីសិទ្ធិ និងច្បាប់
- គោរព លើកកម្ពស់ និងបំពេញសិទ្ធិដល់ស្ត្រីជនជាតិដើមភាគតិច
- លុបបំបាត់អំពើហិង្សាក្នុងគ្រួសារ
- កាត់បន្ថយភាពក្រីក្រ

DPA

DEVELOPMENT AND PARTNERSHIP IN ACTION

Manos Unidas
CAMPAÑA CONTRA EL HAMBRE

SCIAF
Scotland's aid agency

TRÓCAIRE
Working for a Just World

Caritas
AOTEAROA NEW ZEALAND

christian aid

CAFOD
Just one world

CANADIAN CATHOLIC ORGANIZATION FOR
Development and Peace

MISEREOR
DAS HILFSWERK

Oxfam
America

Oxfam Novib

Cord
Peace through Partnership

Health Unlimited

European Union

forum syd

UNDP